ថ្ងៃ ពុធ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅ កំបោរ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទកំបោរ**

ភាយ-ញឿ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កំបោរ |
| ភូមិ | ៖ | កំបោរ និងកណ្តាល |
| ឃុំ | ៖ | ភ្នំលៀប |
| ស្រុក | ៖ | ព្រះនេត្រព្រះ |
| ខេត្ត | ៖ | បន្ទាយមានជ័យ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កំបោរ
ភូមិ ៖ កំបោរ និងកណ្ដាល
ឃុំ ៖ ភ្នំលៀប
ស្រុក ៖ ព្រះនេត្រព្រះ
ខេត្ត ៖ បន្ទាយមានជ័យ

# ជំពូកទី ១
## គោលបំណង និង ទាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍ ការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព។
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការ សម្រាប់ដំណើរការសហគមន៍នេសាទ។
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២.-**

ឈ្មោះសហគមន៍នេសាទ**កំបោរ** ដែលមានអាស័យដ្ឋានភូមិកំបោរ ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

**មានកម្មវត្ថុ**

ដើម្បីថែរក្សា ការពារ ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍និងគ្រប់គ្រងធនធានជលផលឱ្យបានយូរអង្វែង។

# ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និង សិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទមានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ ខាងលើមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា។
- បោះឆ្នោតនិងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទនេះ។
- ទទួលព័ត៌មាន អំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយបើមានការ ស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី( ១/៣ )នៃសមាជិកសហគមន៍នេសាទទាំងអស់។

- ធ្វើនេសាទជាលក្ខណៈគ្រួសារ ស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល។
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ។
- ប្តឹងត៌វា ឬ ផ្តល់ព័ត៌មាន អំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍ របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ។
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវ រាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុស ដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅ អាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ សាមីហើយចំនួនសមាជិកសហគមន៍នេសាទ ដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី(៣)នាក់ចូលរួមប្រជុំដើម្បីចោទសួរ គណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទង នឹងចំណុចដែលបានស្នើឡើងនោះ។

**ប្រការ ៥** .-

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល ។
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ។
- អនុវត្តតាមអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ។
- បង់ប្រាក់សមាជិកភាពចំនួន១.០០០រៀលតាមការសម្រេចរបស់មហាសន្និបាតនៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ។
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន **២០០០រៀល** តាមការសម្រេចរបស់មហាសន្និបាត។
- អ្នកខាងក្រៅសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងសហគមន៍១០០០រៀល ម្តងក្នុង១ថ្ងៃ។
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ។
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ។
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍ រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

**ប្រការ ៦ .-**

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷
- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាម៉ីខ្លួនទទួលមរណភាព
- សាម៉ីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

**ប្រការ ៧ .-**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ÷
- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា។
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទឬសមាជិកសហគមន៍នេសាទដទៃទៀត។
- សាម៉ីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។
- សាម៉ីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និង ឯកសានានា

**ប្រការ ៨ .-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷
- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩ .-**

រាល់ការចំណាយថវិកាសហគមន៍ត្រូវអនុវត្តដូចតទៅ៖
- ការចំណាយពី ១០០រៀល(មួយរយ) ដល់ **៧០,០០០រៀល**(ប្រាំពីរ**ម៉ឺន**រៀល) ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ។
- ការចំណាយពី ៧០,១០០ ដល់ ៧០០,០០០រៀល(ចិតសិបម៉ឺនរៀល) ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ។
- ការចំណាយពីលើសពី៧០០,១០០រៀល ឡើងទៅត្រូវសម្រេច ដោយមហាសន្និបាត។

**ប្រការ ១០ .-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ៖

- ចំណូល ចំណាយថវិកា
- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១ .-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ៖

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះ បញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយគឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២ .-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមានប្រធានអនុប្រធាននិងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូបនិងត្រូវ ពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣ .-**

គណៈកម្មការសហគមន៍នេសាទ មានអាណត្តិប្រាំ(៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើស ក្នុងមហាសន្និបាតឱ្យចូល កាន់តំណែងជំនួស។ក្នុងករណីសហគមន៍នេសាទដំណើរការមិនប្រក្រតីដោយមូលហេតុដំណើរការមិនល្អឬ អសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី(១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ ១៤ .-**

ក្នុងករណី ដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលបី(៣)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសំឡេងគាំទ្រ បន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាត កន្លងមកត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរៀបចំប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥ .-**

គណៈកម្មការសហគមន៍នេសាទ ត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់ រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈ កម្មការសហគមន៍នេសាទ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល ។

**ប្រការ ១៦ .-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលបានការប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបានក្នុងករណីដែលសមាជិក នោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧ .-**

ការសម្រេចលើបញ្ហាណាមួយ របស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសម្លេងស្មើគ្នាមតិប្រធានអង្គប្រជុំជាឧត្តមានុភាព ÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមា ជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហ គមន៍នេសាទត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬ សាលាឃុំ សង្កាត់ក្នុងរយៈពេល ៧ថ្ងៃ យ៉ាងយូរបន្ទាប់ពីការប្រជុំ។

# ជំពូកទី ៧
# មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨ .-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូង របស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធ នឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទធ្វើឡើងដោយក្រុមប្រឹក្សាឃុំសង្កាត់ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទអនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩ .-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញ តាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣)យ៉ាងតិច។

**ប្រការ ២០ .-**

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋានឬ ក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធនិងអ្នកគាំទ្រចូលរួមសង្កេតការណ៍ឬសម្របសម្រួលឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១ .-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈនិងបិទប្រកាសនៅសាលាឃុំសង្កាត់និងទីស្នាក់ការ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួម មហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់(១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣)ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាល នៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាត ដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំ ដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន

- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្ដីសម្រេចរបស់មហាសន្និបាតត្រូវយកសំឡេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកដែលមានវត្តមាន

**ប្រការ ២២ .-**

មហាសន្និបាតអនុម័ត ៖

- សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ លក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្ដេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៤
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣ .-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះ ត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤ .-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាព ពីបី (៣) ទៅប្រាំ(៥)នាក់ដែលមានប្រធានអនុប្រធាននិងសមាជិកតាមការកំណត់ជាក់ស្ដែង របស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានចំណេះដឹងនិងមានសីលធម៌ល្អ។គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្ដេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

**ប្រការ ២៥ .-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម ៖

- ប្រកាសបេក្ខជនឈរឈ្មោះ។
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត។
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ។
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត។
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ។

**ប្រការ ២៦ .-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍ នេសាទ បេក្ខជន ដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការ សហគមន៍ នេសាទតាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជន ដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬ បោះឆ្នោតរក អ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាល នៃចំនួនសមាជិកសហគមន៍នេសាទ ដែល ចូលរួម។

## ជំពូកទី ៥
## លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧ .-**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរ លើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។
- សេចក្តីសម្រេចមហាសន្និបាត ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាតលើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ។

**ប្រការ ២៨ .-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ មាន ភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់ អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេល ប្រកាស លទ្ធផលបោះ ឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច។

**ប្រការ ២៩ .-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទ ដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន។
- ក្នុងករណី គណៈកម្មការសហគមន៍នេសាទ ដោះស្រាយវិវាទនោះពុំបានសម្រេចត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។
- ក្នុងករណីបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបានគណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០ .-**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះត្រូវទទួលទណ្ឌកម្ម ពីគណៈកម្មការសហគមន៍នេសាទ ឬ មហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំឡេងយល់ព្រម លើសពីពាក់កណ្តាល នៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកទី២ នៅថ្ងៃ ចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខារបស់ ប្រធានគណៈកម្មការសហគមន៍នេសាទ។

ថ្ងៃ ចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅ កំពត ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទអំបោរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ កំបោរ |
| ភូមិ | ៖ កំបោរ និងកណ្ដាល |
| ឃុំ | ៖ ភ្នំលៀប |
| ស្រុក | ៖ ព្រះនេត្រព្រះ |
| ខេត្ត | ៖ បន្ទាយមានជ័យ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កំបោរ |
| ភូមិ | ៖ | កំបោរ និងកណ្ដោល |
| ឃុំ | ៖ | ភ្នំលៀប |
| ស្រុក | ៖ | ព្រះនេត្រព្រះ |
| ខេត្ត | ៖ | បន្ទាយមានជ័យ |

# ចនបញ្ញាផ្ទៃក្នុង
# កន្លែងនេសាទសហគមន៍នេសាទកំបោរ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ**កំបោរ** សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ÷

**ប្រការ ១.**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចំរើនរបស់សហគមន៍នេសាទ។

**ប្រការ ២.**

គណៈកម្មការសមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬ បុគ្គលដទៃទៀត ត្រូវសងឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច។
- ចំពោះគណៈកម្មការសហគមន៍នេសាទ ត្រូវសង ឬ ទូទាត់សងការខូចខាតតាមការសម្រេចរបស់មហា-សន្និបាតប្រសិនបើនីតិវិធីខាងលើនេះ នៅតែមិនអាចដោះស្រាយបានគឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣.**

សមាជិកសហគមន៍នេសាទ គ្រប់រូបត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមរយៈកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួបជុំចំនួន៣ដងជាប់គ្នា ដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤.**

សិទ្ធិដាក់ទណ្ឌកម្ម ÷

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទនិងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល។

ចំពោះការនេសាទលើសទំហំ ចំនួន និង ខុសប្រភេទ ពេលវេលា ទីតាំង តាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និង កិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ- មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬ បុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

**ប្រការ ៥ .**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈ ឧបករណ៍នេសាទដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦ .**

សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍នៅកក្នុងរដូវបើក និងបិទនេសាទ ផ្អែកតាមប្រកាសលេខៈ ៤៥៨ ប្រក.កសក ចុះថ្ងៃទី២២ ខែតុលាឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែល អនុញ្ញាតឱ្យប្រើធ្វើនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា និងផ្អែកតាមផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ៤៥៨ ប្រក កសក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្តីពី "**ការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារដែលអនុញ្ញាតឲ្យធ្វើការនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា**"

**សម្រាប់រដូវ បិទនេសាទ**

| ល.រ | ឈ្មោះឧបករណ៍នេសាទ | ចំនួន | ម៉ែត្រ | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ០១ | កង្វារកង្កែប ក្តាម | | | |
| ០២ | កង្វារត្រីឆ្លូញ | | | |
| ០៣ | កញ្ជ្រែងជញ្ជាត់(កញ្ជ្រែងដងត្រី) | | | |
| ០៤ | កន្ទុំ | | | |
| ០៥ | ចង្រប់ | | | |
| ០៦ | ចាន់ | | | |
| ០៧ | ច្បូក | | | មិនប្រើកែវថ្លុះរួមផ្សំ |
| ០៨ | ជិត | | | |
| ០៩ | ជុច | | | |
| ១០ | ដូអន្ទង់ | | | |
| ១១ | ឈ្នាងដៃ(ឈ្នាងជញ្ជត់) | | | |
| ១២ | ឈ្នាងត្រាំ | | | |

| | | | | |
|---|---|---|---|---|
| ១៣ | ឈ្នាងអួសឬក្រញូខ្មៅ ឬលាស | | | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១៤ | ឈ្នាងកង | | | |
| ១៥ | ដែកាប់ | | | |
| ១៦ | ដែកឈ្នៀត | | | |
| ១៧ | ដែកចាក់មានងៀង | | | |
| ១៨ | តុម | | | |
| ១៩ | ថ្នង | | | |
| ២០ | ទ្រូ | | | |
| ២១ | ប្រម | | | |
| ២២ | ប៉ោងត្រីឆ្លាំង | | | |
| ២៣ | បំពង់ត្រីកញ្ជ្រូក | | | |
| ២៤ | ប៉ោង | | | |
| ២៥ | មងបណ្តែត | | មិនលើសពី១០០ម៉ែត្រ | |
| ២៦ | មងពាក់ | | មិនលើសពី១០០ម៉ែត្រ | |
| ២៧ | លាយ | | | |
| ២៨ | លប | | | មិនប្រើបាំងព្រួលរួមផ្សំលើសពី១០ម៉ែត្រ ឬមិនលើសពី១/៣នៃទទឹងមុខទឹក |
| ២៩ | លាន់អន្ទង់ | | | |
| ៣០ | សម | | | |
| ៣១ | ស្ន | | | |
| ៣២ | សាង | | | មិនប្រើកែវឆ្លុះរួមផ្សំ |
| ៣៣ | សៃយ៉ឺន | | | មិនប្រើបាំងព្រួលរួមផ្សំលើសពី១០ម៉ែត្រ ឬមិនលើសពី១/៣នៃទទឹងមុខទឹក |
| ៣៤ | សៃយ៉ឺនកំពិស | | | |
| ៣៥ | សន្ទូចផ្លែមួយ | | | |
| ៣៦ | សន្ទូចបោះ | | | |
| ៣៧ | សន្ទូចបបក់ | | | |
| ៣៨ | សន្ទូចបង្កៃ | | | |
| ៣៩ | សន្ទូចរនង | | | |
| ៤០ | ស៊ងត្រីកញ្ចុះ | | | |
| ៤១ | សំណាញ់ | | | |
| ៤២ | ទ្បើ | | | |
| ៤៣ | អង្រុត | | | |
| ៤៤ | អញ្ចង | | | |

## ឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ៤៥៨ ប្រក កសក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្តីពី "**ការកំណត់ ប្រភេទឧបករណ៍នេសាទ ត្រូវសារដែលអនុញ្ញាតឲ្យធ្វើការនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា**"

**សម្រាប់ជួង ម៉ើកនេសាទ**

| ល.រ | ឈ្មោះឧបករណ៍នេសាទ | សេចក្តីផ្សេងៗ |
|---|---|---|
| ០១ | កង្វារកង្កែប ក្តាម | |
| ០២ | កង្វារត្រីឆ្តូញ | |
| ០៣ | កញ្ច្រែងជញ្ជាត់(កញ្ច្រែងជងត្រី) | |
| ០៤ | កន្ទុំ | |
| ០៥ | ចង្រង់ | |
| ០៦ | ចាន់ | |
| ០៧ | ចៃ៉ា | មិនប្រើម៉ាស៊ីនរុញនិងខ្យល់រួមផ្សំ |
| ០៨ | ច្បូក | មិនប្រើកែវឆ្លុះរួមផ្សំ |
| ០៩ | ជន | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១០ | ជិត | |
| ១១ | ជុច | |
| ១២ | ជូអន្ទង់ | |
| ១៣ | ឈ្នាងដៃ(ឈ្នាងជញ្ជូត់) | |
| ១៤ | ឈ្នាងត្រាំ | |
| ១៥ | ឈ្នាងអូសឬញខ្ចៅ ឬលាស | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១៦ | ឈ្នាងកង | |
| ១៧ | ឈ្នក់(ឆ្នុក) | មិនប្រើភ្លើងនិងនុយរួមផ្សំ |
| ១៨ | ដៃកាប់ | |
| ១៩ | ដៃកឡៀត | |
| ២០ | ដែកចាក់មានងៀង | |
| ២១ | តុម | |
| ២២ | ថ្នង | |
| ២៣ | ទ្រូ | |
| ២៤ | នាម | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ២៥ | ប្រម | |
| ២៦ | ប៉ោងត្រីឆ្តាំង | |
| ២៧ | បំពង់ត្រីកញ្ជ្រូក | |
| ២៨ | ប៉ោង | |
| ២៩ | មងបណ្តែត | |

| | | |
|---|---|---|
| ៣០ | មងពាក់ | |
| ៣១ | លាយ | |
| ៣២ | លប | មិនប្រើបាំងព្រួលលើសពី១/២ នៃទទឹងមុខទឹក |
| ៣៣ | លាន់អន្ទង់ | |
| ៣៤ | សម | |
| ៣៥ | ស្ទ | |
| ៣៦ | សាង | មិនប្រើកែវវត្ថុរួមផ្សំ |
| ៣៧ | សៃយ៉ឺន | មិនប្រើបាំងព្រួលលើសពី១/២ នៃទទឹងមុខទឹក |
| ៣៨ | សៃយ៉ឺនកំពិស | |
| ៣៩ | សន្ទូចផ្លែមួយ | |
| ៤០ | សន្ទូចបោះ | |
| ៤១ | សន្ទូចបបក់ | |
| ៤២ | សន្ទូចបង្កៃ | |
| ៤៣ | សន្ទូចរនង | |
| ៤៤ | ស៊ងត្រីកញ្ចុះ | |
| ៤៥ | សំណាញ់ | |
| ៤៦ | ឡើ | |
| ៤៨ | អង្រុត | |
| ៤៩ | អញ្ចង | |
| ៥០ | អួនអូសដោយដៃ | ប្រវែងមិនលើសពី១០០ម៉ែត្រ |

+++ ក. រដូវបិទនេសាទចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ ថ្ងៃទី៣០ ខែកញ្ញា

+++ ខ. រដូវបើកនេសាទចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ ថ្ងៃទី៣១ ខែឧសភា

❖ **ឧបករណ៍នេសាទដែលត្រូវហាមឃាត់ជាដាច់ខាត៖**

ហាមឃាត់ដាច់ខាតចំពោះ ការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទឬកន្លែងនេសាទសហគមន៍ដោយប្រើប្រាស់ឧបករណ៍ដូចខាងក្រោម៖

- ឧបករណ៍ឆក់គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ។
- ឧបករណ៍ ឬមធ្យោបាយពង្រីងផ្ទៃកណាមួយនៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល។
- សម្រាប់ ឬមធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រីឬវារីសត្វកុំ។
- ច្បូក សាង ស្ទ ឬ ឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ។
- មងបោះ មងកាំង ឬមងពស់ថ្លាន់គ្រប់ប្រភេទ។
- មងឬអួនគ្រប់ប្រភេទ ដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ(១.៥ស.ម) ក្នុងដែននេសាទទឹកសាបឬ កន្លែងនេសាទសហគមន៍។

- មងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំសង្ទីម៉ែត្រ (១៥ស.ម) ក្នុងដែននេសាទទឹកសាប ឬ កន្លែងនេសាទសហគមន៍។
- អួនអូសគូ ឬ អួនហ៊ុម្ភមផ្សំភ្លើង ដែលធ្វើឱ្យត្រី ឬវារីសត្វកុំ។
- ឧបករណ៍នេសាទស្នែមុងគ្រប់ប្រភេទនៅទឹកសាប។
- អួនអូសគ្រប់ប្រភេទ និងឈិបយន្តនៅទឹកសាប។
- ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ(១.៥ស.ម)ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។
- ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ។
- ឧបករណ៍នេសាទទំនើបឬឧបករណ៍នេសាទដែលបង្កើតថ្មីឬរបៀបនេសាទបែបថ្មីដែលនាំមកនូវការបំផ្លាញមច្ឆាជាតិ។
- ហាមឃាត់ការផលិតការទិញការលក់ការដឹកជញ្ជូនការរក្សាទុកឧបករណ៍ឆក់ឧបករណ៍នេសាទស្នែមុងគ្រប់ប្រភេទ
- អួសអូសគូឈិបយន្ត និងអួនអូសទឹកសាបក្នុងគោលបំណងធ្វើនេសាទ។
- ហាមឃាត់ការចាក់ចោលការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទ នូវកាកសំណល់រឹង ឬរាវឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ នៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាឬ សន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថានឬ ការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុលឬ បង្កការគ្រោះថ្នាក់ដល់វារីសត្វនិងវារីរុក្ខជាតិ។
- ហាមដាច់ខាត ការធ្វើនេសាទគ្រប់ប្រភេទ នៅអន្លង់អភិរក្សឬ កន្លែងអភិរក្សត្រីមេពូជ។

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទដែល ÷

- ប្រព្រឹត្តផ្ទុយ ឬ រារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត។
- មិនចូលរួមថែរក្សាការពារ ធនធានជលផលឬ មិនរាយការណ៍ អំពីសកម្មភាពបទល្មើសជលផលត្រូវប្រមានដោយគណៈកម្មការសហគមន៍នេសាទ។
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ធ្វើនេសាទខុសច្បាប់ កាប់ ឆ្កា រានព្រៃលិចទឹក ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល។
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច។
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងកិច្ចព្រមព្រៀង ឬ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បី ដោះស្រាយតាមច្បាប់។

**ប្រការ ៨..**

ចំពោះអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពតាមកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ក្នុងករណី ដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទ មានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ។

**ប្រការ ៩.**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកទី២ នៅថ្ងៃពុធ ១០ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ថ្ងៃពុធ ១០ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅ កំពត ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទកំបោរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ កំបោរ |
| ភូមិ | ៖ កំបោរ និងកណ្តាល |
| ឃុំ | ៖ ភ្នំលៀប |
| ស្រុក | ៖ ព្រះនេត្រព្រះ |
| ខេត្ត | ៖ បន្ទាយមានជ័យ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទកំបោរ

ក្រោយពិការកែទំរង់លើវិស័យជលផល រាជរដ្ឋាភិបាលបានកាត់ផ្ទៃឡូត៍នេសាទ ទុកសំរាប់ប្រជាពលរដ្ឋស្មើរនឹង៨០.៤២% នៃផ្ទៃក្រលាឡូត៍នេសាទទាំងអស់ ក្នុងខេត្តបន្ទាយមានជ័យ ផ្តល់ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ។

យើងខ្ញុំសូមគោរពជំរាប ឯកឧត្តមប្រធានរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ ឡើងក្រោយពីភាពតានតឹង នៃជីវភាពរស់នៅរបស់ប្រជានេសាទ ដែលបណ្តាលមកពីដែននេសាទតូចចង្អៀត ភាពអណាធិបតេយ្យ នៃការនេសាទខុសច្បាប់ និងទំនាស់ដែននេសាទធ្វើអោយប្រជាពលរដ្ឋក្នុងភូមិពីរគឺភូមិកំបោរ និងភូមិកណ្តោល ក្នុងឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ បានឯកភាពគ្នាធ្វើសំណើរ និងព្រមព្រៀងគ្នាបង្កើតសហគមន៍នេសាទនេះឡើង ក្នុងគោលបំណង ចូលរួមចំណែកគ្រប់គ្រងការពារ អភិរក្ស និងអភិវឌ្ឍន៍ដែននេសាទសហគមន៍។ បន្ទាប់ពីមានការយល់ព្រមពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រជាជនក្នុងភូមិទាំងពីរ និងភូមិដែលរស់នៅជាប់ភូមិសាស្រ្ត ត្រូវបានបើកទូលាយអោយប្រជាពលរដ្ឋក្នុងភូមិមានសិទ្ធិប្រកបមុខរបរនេសាទជាលក្ខណៈគ្រួសារ។ សហគមន៍នេសាទកំបោរ ត្រូវបានបង្កើតឡើង ដោយខណ្ឌរដ្ឋបាលជលផល ខេត្តបន្ទាយមានជ័យ និងមានការជួយជ្រោមជ្រែងពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ គណៈកម្មការសហគមន៍នេសាទកំបោរ ត្រូវបានជ្រើសរើសឡើងតាមរយៈ ការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ ចេញពីប្រជាពលរដ្ឋក្នុងភូមិ។ សហគមន៍នេសាទកំបោរ ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទចំនួន៩ នាក់ ស្រី០១ នាក់ ហើយមានសមាជិកសហគមន៍ចូលរួមសរុបចំនួន៩៧១ នាក់ ,ស្រី ៥០៣ នាក់ និងមានដែនទីកន្លែងនេសាទសហគមន៍ ដែលត្រូវគ្រប់គ្រងសរុប៦.៨៧០ ហិកតា ក្នុងនោះកន្លែងអភិរក្ស២កន្លែង គឺស្ទឹងកំបោរ ត្រង់ចំណុចអន្លង់អ៊ុយ ទំហំ ៣.៣៧ ហិកតា និងរហាលថ្លាត ទំហំ ៥ ហិកតា ។

ចាប់តាំងពីឆ្នាំ២០០៤ សហគមន៍នេសាទកំបោរ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនមួយចំនួនដូចជាៈ ផ្សព្វផ្សាយច្បាប់ជលផល ចូលរួមវគ្គបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ ការសរសេររបាយការណ៍ ការដោះស្រាយទំនាស់ ផែនការគ្រប់គ្រង ទស្សនៈកិច្ចសន្សាសិក្សា ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ ប្រជុំបណ្តាញកំរិតស្រុក-ខេត្ត ល្បាតទប់ស្កាត់បទល្មើស ដោះស្រាយទំនាស់នេសាទ កំណត់ព្រំប្រទល់ រៀបចំផែនទីកន្លែងនេសាទសហគមន៍ បង្កើតកន្លែងអភិរក្សពូជត្រី២កន្លែង ចូលរួមពង្រាង លក្ខន្តិកៈ រៀបចំផែនការគ្រប់គ្រង ផ្សព្វផ្សាយពីយេនឌ័រ ប្រជុំប្រចាំខែ ដោយមានការជួយគាំទ្រ ពីអង្គការ ក្រុមទ្រទ្រង់ភូមិ (VSG) សហការជាមួយ ខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន។ ទន្ទឹមនឹងនេះសហគមន៍យើងខ្ញុំបាន

រៀបចំនូវឯកសារួចរាល់ជាស្ថាពរ ដូចមានចែងក្នុងអនុក្រឹត្យសហគមន៍នេសាទ ដែលរួមមាន កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រង បញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍។ ដើម្បីឱ្យយន្តការគ្រប់គ្រងនិងដឹកនាំស្របតាមលក្ខណៈច្បាប់សហគមន៍នេសាទកំបោរ បានរៀបចំមហាសន្និបាតសហគមន៍ ដើម្បីអនុម័តលើឯកសារទាំងអស់នេះ ឱ្យស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងគោលការណ៍ណែនាំ សហគមន៍ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១០ ។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ ក្នុងការប្រគល់ដែននេសាទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋជាផ្លូវការពីភាគី ក (នាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ) ឱ្យទៅភាគី ខ (ប្រធានគណៈកម្មការសហគមន៍នេសាទ) ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ។ ដោយផ្អែកលើសមិទ្ធិផលដូច បានរៀបរាប់ខាងលើ និងការប្រជុំឯកភាពគ្នារវាងគណៈកម្មការ និងសមាជិកសហគមន៍នេសាទរួចមក យើងខ្ញុំជាគណៈកម្មការតំណាងឱ្យសហគមន៍នេសាទ**កំបោរ** សូមគោរពជូន ឯកឧត្តមប្រធានរដ្ឋបាលជលផលនូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែលមានភ្ជាប់មកជាមួយនូវ បញ្ជីឈ្មោះសមាជិកសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនទីគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសំរេច ដោយក្តីអនុគ្រោះ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទ**កំបោរ** សូមធ្វើកាប្តេជ្ញាចិត្ត និងសន្យាថា នឹងខិតខំដឹកនាំគ្រប់គ្រងសហគមន៍នេសាទ ឱ្យមានភាពរីកចំរើន ដោយគោរពទៅតាមគោលការណ៍ លក្ខន្តិកៈ និងបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទ និងច្បាប់លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល។ បើសិនជាយើងខ្ញុំបានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើយើងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

*សូមឯកឧត្តមប្រធានមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។*

ថ្ងៃ ពុធ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅ កំបោរ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទកំបោរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | កំបោរ |
| ភូមិ | ៖ | កំបោរ និងកណ្តាល |
| ឃុំ | ៖ | ភ្នំលៀប |
| ស្រុក | ៖ | ព្រះនេត្រព្រះ |
| ខេត្ត | ៖ | បន្ទាយមានជ័យ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទកំបោរ**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ**

**កម្មវត្ថុ** : សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍**កំបោរ**។

**យោង** : - អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

- មហាសន្និបាតលើកទី២ របស់សហគមន៍នេសាទ ធ្វើនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨។

**លិខិតភ្ជាប់** : កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍**កំបោរ**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន លោកនាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ មេត្តាជ្រាបថាសហគមន៍នេសាទ**កំបោរ** បានបង្កើតឡើងដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើម ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងភូមិកំបោរនិងភូមិកណ្តាល ឃុំភ្នំលៀប ស្រុកព្រះនេត្រ-ព្រះ ខេត្តបន្ទាយមានជ័យ។ ចាប់តាំងពីធ្វើមហាសន្និបាតកំណើតដំបូងរបស់នេសាទសហគមន៍**កំបោរ**គណៈកម្មការសហគមន៍ និងសមាជិកសហគមន៍នេសាទ បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយរដ្ឋបាលជលផលខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ និងអាជ្ញាធរដែនដី។

**លទ្ធផលដែលទទួលបានគួរឱ្យកត់សម្គាល់មានដូចជា៖**

- បញ្ជីឈ្មោះ គណៈកម្មការសហគមន៍ និងសមាជិកសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- រចនាសម្ព័ន្ធ របស់សហគមន៍នេសាទ
- ផែនទីកន្លែងនេសាទសហគមន៍ មាត្រដ្ឋាន ១/៥០.០០០
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សហការយាមល្បាតកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមបង្ក្រាបបទល្មើសនេសាទ
- ទប់ស្កាត់ការពង្រីកដីកសិកម្ម
- ការពារព្រៃលិចទឹក។

យោងតាមសកម្មភាពនិងលទ្ធផលដែលទទួលបានប្រធានគណៈកម្មការសហគមន៍នេសាទ**កំបោរ** សូមស្នើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ អាស្រ័យហេតុដូចនេះសូមលោកនាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យមេត្តាពិនិត្យលើលទ្ធភាពនិងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍**កំបោរ** តាមការស្នើសុំខាងលើព្រមទាំងផ្តល់ការគាំទ្រ ដល់សហគមន៍នេសាទរបស់យើងខ្ញុំដើម្បីគ្រប់គ្រងធនធានជលផលនិងប្រើប្រាស់ធនធានជលផលក្នុងតំបន់ឱ្យទទួលបានជោគជ័យសម្រាប់កូនចៅជំនាន់ក្រោយ។

សូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃ ពុធ ១០ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅ កំបោរ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានគណៈកម្មការសហគមន៍នេសាទកំបោរ**

# កំណត់ហេតុស្តីពី

ការប្រជុំកំណត់ចំណុចគោលដៅ គ្រោះមហន្តរាយ

ក្រុមប្រឹក្សាកម្មវិធីស្តារនីតិសម្បទាសហគមន៍ កំពង់ត្រាច សម្រាប់ស្ត្រីជនពិការសហគមន៍

[illegible] ខែ កញ្ញា [illegible] ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

បានបើកការប្រជុំស្តីពី៖ ការកំណត់ក្រុមប្រឹក្សាចំណុចគោលដៅ កម្មវិធីស្តារនីតិសម្បទា សម្រាប់ស្ត្រីជនពិការសហគមន៍ក្រោមអធិបតីភាព លោក ឡុញ វុធី នាយករដ្ឋបាលស្រុក បន្ទាយមានជ័យ ខេត្តបន្ទាយមានជ័យ ។

សមាសភាពចូលរួមមានដូចជា ក្រុមប្រឹក្សា សូវ បញ្ជីវត្តមាន ៖

1. លោក ឡុញ វុធី នាយករដ្ឋបាលស្រុក បន្ទាយមានជ័យ
2. លោក សួន សុភៅ នាយករងរដ្ឋបាលស្រុក ព្រះនេត្រព្រះ
3. លោក ភឿន ចេង ប្រធាន ការិយាល័យ អភិវឌ្ឍន៍ ផ្នែក ភាគ សហគមន៍
4. លោកស្រី ផាន់ ចៅ អនុប្រធាន ការិយាល័យ អភិវឌ្ឍន៍ ផ្នែក ភាគ សហគមន៍

សេចក្តីផ្តើមនៃការប្រជុំ កំណត់ក្រុមប្រឹក្សាចំណុចគោលដៅ កម្មវិធីស្តារ សហគមន៍ កំពង់ត្រាច ស្ត្រីជនពិការសហគមន៍ លោក ឡុញ វុធី នាយករដ្ឋបាលស្រុក បន្ទាយមានជ័យ បានពន្យល់ សហគមន៍ កំពង់ត្រាច មិនទាន់បានចុះបញ្ជី និង ការទទួលស្គាល់ ពីក្រសួងមហាផ្ទៃ ។

បន្ទាប់មក លោក សួន សុភៅ បាន ធ្វើបទបង្ហាញ ការងារ ស្តារ សមាជិក សមត្ថភាព អ្នកចូលរួម សហគមន៍ ជនពិការ ចំនួន 04 ចំណុច គឺ៖

- ចំណុច ទីចប់រំលោញ
- ចំណុច ទាមទារសិទ្ធិ ធនធាន
- ចំណុច ទាមទារ គ្រោះ ឈឺ ក្រុមគ្រួសារ
- ចំណុច ទាមទារ ទឹក ទាមទារ គ្រោះ ធម្មជាតិ

តាមរយៈ ការបង្ហាញ ក្នុងឆ្នាំ 2008 ដល់ 2015 ការកំណត់ក្រុមប្រឹក្សាគោលដៅ សហគមន៍ជនពិការ កំពង់ត្រាច បានតាមការ សកម្មភាព ពីខណ្ឌរដ្ឋបាលស្រុក ខេត្តបន្ទាយមានជ័យ និង ក្រុមការងារ បកប្រែ រដ្ឋបាល ភ្នំពេញ ចំណុចគោលដៅ ដូច ក្នុងតារាង ២

ចំណុចគោលរបស់ដែនចាំៗសំរាប់ចុះបញ្ជីសហគមន៍ (G.P.S) គាប់ស៊ុល និង
ស៊ែរ ណារ៉ាគេ ស៊ុច ណាង ព្រោះ

និយាយការសហគមន៍ទន្លេសាប ។

ចំណុចទី 1 x = 316696 y = 1501000 ចំណុចពាមព្រែកស្ទឹង...

ចំណុចទី 2 x = 318000 y = 1498000 ចំណុចទីរប់ទីរចំណុច

ចំណុចទី3 x = 316666 y = 1496121 ចំណុចពាមព្រែកស្ទឹងពាមរាង

ចំណុចទី 4 x = 315636 y = 1492212 ចំណុចពាមព្រែកស្ទឹង...
ទាប់

ចំណុចទី 5 x = 314242 y = 1490636 ចំណុចពាមព្រែកព្រៃកណ្តាល

ចំណុចទី 6 x = 313454 y = 1490636 ចំណុចពាមជើងក្រោម...

ចំណុចទី 7 x = 312480 y = 1492939 ចំណុចកំពង់ត្រៀ

ចំណុចទី 8 x = 312646 y = 1489163 ចំណុចក្រោមកក់

ចំណុចទី 9 x = 308520 y = 1491909 ចំណុចទីរប់ក្រពើ

ចំណុចទី10 x = 310212 y = 1493939 ចំណុចពាមព្រែក...
តាត្បែង

ចំណុចទី 11 x = 310000 y = 1501000 ចំណុចពាមព្រែកក្រោមក្តាម

សាមីបញ្ចប់ពាក្យ ឬ ទីធ្លី បានធ្វើឡើងក្នុងភូមិនិងមានបញ្ចប់ដែលគណ
ការសហគមន៍ទន្លេសាប...
...
...
...
កំណត់ហេតុបានបញ្ចប់...ចំណុចចំនួន 11 ចំណុចពាមព្រែក...នៅម៉ោង 4 និង 40 នាទី
ថ្ងៃទី 05 ខែ កក្កដា ឆ្នាំ 2018 ។

ប្រធានសហគមន៍ទន្លេសាប

អ្នកធ្វើកំណត់ហេតុ

ហាស ស៊ីវ៉ន

## បញ្ជីវត្តមានអ្នកចូលរួម ស្តីពី

ការប្រជុំ......[illegible]......

ភូមិ...[illegible]... ឃុំ...[illegible]... ស្រុក...ព្រះនេត្រព្រះ... ខេត្ត...បន្ទាយមានជ័យ...

ថ្ងៃ.........................ខែ..............ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ថ្ងៃទី...០៥.....ខែ...កញ្ញា.....ឆ្នាំ២០១៨

| ល.រ | ឈ្មោះអ្នកចូលរួម | ភេទ | តួនាទីនិងអាសយដ្ឋាន | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|
| 01 | [illegible] | ប | [illegible] | 012955563 | [signature] |
| 02 | [illegible] | ប | [illegible] | 012899886 | |
| 03 | [illegible] | ប | [illegible] | 017746927 | [signature] |
| 04 | [illegible] | ស | [illegible] | 012262116 | [signature] |
| 05 | [illegible] | ប | [illegible] | 012580657 | [signature] |
| 06 | [illegible] | ស | [illegible] | 096365564 | [signature] |
| 07 | [illegible] | ប | [illegible] | 0687064147 | [signature] |
| 08 | [illegible] | ប | [illegible] | 012428372 | [signature] |
| 09 | [illegible] | ប | សមាជិកភូមិកំពង់ | 060417629 | [signature] |
| 10 | [illegible] | ប | សមាជិកភូមិកំពង់ | | [signature] |
| 11 | [illegible] | ប | សមាជិកភូមិកំពង់ | | [signature] |
| 12 | [illegible] | ប | សមាជិកភូមិកំពង់ | | [signature] |
| 13 | [illegible] | ស | សមាជិកភូមិកំពង់ | | [signature] |
| 14 | [illegible] | ស | សមាជិកភូមិកំពង់ | | [signature] |
| 15 | [illegible] | ប | —"— | | [signature] |
| 16 | [illegible] | ប | —"— | | [signature] |
| 17 | [illegible] | ប | [illegible] | | [signature] |
| 18 | [illegible] | ប | [illegible] | | [signature] |
| 19 | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៤២៩ ប្រក.កសក

# ប្រកាស
# ស្តីពី
# ការចុះបញ្ជីសហគមន៍នេសាទចំនួន១៣ នៅខេត្តត្បូងឃ្មុំ តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- បានឃើញប្រកាសលេខ០០៣ ប្រក.កសក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីសហគមន៍នេសាទចំនួន១៧ នៅខេត្តក្រចេះ កំពង់ចាម និងខេត្តព្រៃវែង
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ១ .-**

ត្រូវបានចុះបញ្ជីសហគមន៍នេសាទចំនួន១៣ ដូចខាងក្រោម៖

- ខេត្តត្បូងឃ្មុំមានសហគមន៍នេសាទចំនួន០៤ គឺសហគមន៍នេសាទបឹងវាំង សហគមន៍នេសាទបឹងចំណារ សហគមន៍នេសាទក្រូចឆ្មារ និងសហគមន៍នេសាទពោធិ៍និល
- ខេត្តតាកែវមានសហគមន៍នេសាទចំនួន០២ គឺសហគមន៍នេសាទព្រែកផ្ដៅលនិងសហគមន៍នេសាទពោធិ៍-រំចាក
- ខេត្តកំពង់ឆ្នាំងមានសហគមន៍នេសាទចំនួន០២ គឺសហគមន៍នេសាទផ្លូវទូកនិងសហគមន៍នេសាទប្រឡាយ-មាស
- ខេត្តពោធិ៍សាត់មានសហគមន៍នេសាទចំនួន០២ គឺសហគមន៍នេសាទបឹងជងទឹកលាចនិងសហគមន៍នេសាទបឹងព្រះពន្លៃ
- ខេត្តបន្ទាយមានជ័យមានសហគមន៍នេសាទចំនួន០៣ គឺសហគមន៍នេសាទរូបរូម សហគមន៍នេសាទកំបោរ និងសហគមន៍នេសាទដង្កៀបក្ដាមមានជ័យ។

ចំនួនសមាជិក ចំនួនសមាជិកគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសនេះ។

**ប្រការ២ .-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍នៃប្រកាសនេះ អាចធ្វើការកែប្រែបានតាមការចាំបាច់ ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -រដ្ឋបាលខេត្តពាក់ព័ន្ធ
- -ដូចប្រការ៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ** ៖ ភ្ជាប់ប្រកាសលេខ....៤២៨...ប្រក.កសក............. ចុះថ្ងៃព្រហស្បតិ៍.....១២កើត........ ខែ.ពិសាខ... ឆ្នាំកុរ.... ឯកស័ក ព.ស២៥៦៣
ត្រូវនឹងថ្ងៃទី..១៦......... ខែ..ឧសភា............ ឆ្នាំ២០១៩

## សហគមន៍នេសាទក្នុងខេត្តត្បូងឃ្មុំ តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិកប្រុស (ស្រី) | ចំនួនសមាជិកគណៈកម្មការសហគមន៍(ស្រី) | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១. ខេត្តត្បូងឃ្មុំ** | | | | | | | | | |
| ១ | បឹងរាំង | ៥៦ (១) | ៥(0) | ២.៧៧៨,៥៣ | -ក្ដុលលើ<br>-ក្ដុលកណ្ដាល<br>-ក្ដុលក្រោម<br>-ទ្រាទី១<br>-ទ្រាទី២<br>-ទ្រាទី៣<br>-ទ្រាទី៤<br>-ទ្រាទី៥ | ទ្រា | ក្រូចឆ្មារ | A(563113,1357425)<br>B(562198,1356374)<br>C(561270,1355060)<br>D(560958,1354564)<br>E(560835,1353930)<br>F(560549,1353990) | G(560113,1351997)<br>H(560130,1351324)<br>I(560085,1351121)<br>J(565967,1349344)<br>K(567436,1350103) |
| ២ | បឹងចំណារ | ៨៣ (៣៩) | ១១(0) | ៣.២៨៥,៣ | -ទី១<br>-ទី២<br>-ទី៣<br>-ទី៤<br>-ទី៥<br>-ទី៦ | ព្រែកអាជី | ក្រូចឆ្មារ | A(560085,1351121)<br>B(565967,1349344)<br>C(564134,1343709)<br>D(561888,1342543)<br>E(561574,1343809)<br>F(561335,1344289) | G(561223,1345019)<br>H(561104,1345466)<br>I(560617,1346686)<br>J(560278, 1348147)<br>K(560106, 1349461) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | ក្រូចឆ្មារ | ១៤០ (៨៥) | ១១(០) | ២.៦៤៦.៣ | -ក្រូចឆ្មារលើ<br>-ក្រូចឆ្មារក្រោម<br>-ខ្សាច់ប្រឆេះ<br>-កណ្ដាល<br>-ខ្សាច់ប្រឆេះលើ<br>-ខ្សាច់ប្រឆេះក្រោម<br>-ដើមជ្រៃ<br>-សំរោង | ក្រូចឆ្មារ | ក្រូចឆ្មារ | A(563113,1357425)<br>B(564593,1358275)<br>C(566422,1358511)<br>D(567772,1358661) | E(569696,1357465)<br>F(570120,1356648)<br>G (569127,1350087)<br>H (567436,1350103) |
| ៤ | ពោធិ៍និល | ១៧៣(៣៦) | ១១(០) | ៨,៥៩ | -ជៀសទី១<br>-ជៀសទី២<br>-ដូង<br>-គក | ថ្មពេជ្រ | ត្បូងឃ្មុំ | A(568530,1332596)<br>B(568730,1332604) | C(568804,1332177)<br>D(568604,1332169) |
| **២. ខេត្តតាកែវ** | | | | | | | | | |
| ១ | ព្រៃកផ្ទោល | ២៧០(៨៤) | ១១ (០) | ១.០៤២ | -ភ្នំបូរី<br>-បាទេព<br>-កំពង់ពោធិ៍<br>-អង្គរ | ព្រៃកផ្ទោល | អង្គរបុរី | A(496942,1214771)<br>B(495473,1213267)<br>C(494425,1209802)<br>D(496484,1208732)<br>E(495424,1207093) | F(498956,1203406)<br>G(499029,1212982)<br>H(503051,1213017)<br>I (503083,1214755)<br>J (499704,1215583) |
| ២ | ពោធិ៍រំចាក | ២៧៥(១០៥) | ៧ (១) | ៨៤០ | -ស្វាយសំរោង<br>-គោកអង្គង់<br>-ព្រៃតាពង | ពោធិ៍រំចាក | ព្រៃកប្បាស | A(502328,1226734)<br>B(502376,1226734)<br>C(502010,1226304)<br>D(501666,1226265) | E(501582,1226012)<br>F(501532,1226314)<br>G(501623,1226014)<br>H(501881,1226315) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **៣. ខេត្តកំពង់ឆ្នាំង** | | | | | | | | | |
| ១ | ផ្លូវទូក | ១៨២(៧៨) | ១១(១) | ៦.៧៤០ | -ពាមខ្នង<br>-ថ្នល់ឈើទាល<br>-ស្លូត | ផ្លូវទូក | កំពង់លែង | A(450043,1385586)<br>B(451632,1384665)<br>C(452527,1384979)<br>D(455097,1384556)<br>E(457060,1384292)<br>F(460879,1382005)<br>G(460850,1385852) | H(463735,1386932)<br>I (464509,1388365)<br>J (455932,1392663)<br>K(452925, 1389934)<br>L(454548, 1386882)<br>M(454321,1385783) |
| ២ | ប្រឡាយមាស | ៣៩១(១៩៨) | ៩(0) | ៣.១៥០ | ប្រឡាយមាស | ប្រឡាយមាស | កំពង់លែង | A(459492,1382389)<br>B(461629,1378317)<br>C(461149,1376268)<br>D(461010,1376273)<br>E(461831,1372346)<br>F(462289,1372350)<br>G(461406,1368973)<br>H(460549,1369118)<br>I (459212,1372008)<br>J (458869,1372135) | K(458709, 1372551)<br>L(460051, 1371623)<br>M(460117,1372147)<br>N(459968,1372320)<br>O(459986,1372707)<br>P(458293,1373631)<br>Q(457676,1375233)<br>R(457872,1376604)<br>S(458869,1379843)<br>T(458976,1382158) |
| **៤. ខេត្តពោធិ៍សាត់** | | | | | | | | | |
| ១ | បឹងដងទឹកលាច | ៤៣៩(១២៤) | ១១(១) | ១៣៥ | -ដងទឹកលាច<br>-ចំបក់ធំ<br>-កណ្តាល<br>-បឹងវាល<br>-តាកែវលើ | ត្នោតជុំ | ក្រគរ | A(390404,1375203)<br>B(390492,1375241)<br>C(392127,1376947)<br>D(393765,1378628)<br>E(392577,1380159)<br>F(392650,1381665) | G(391192,1384647)<br>H(391111,1384680)<br>I(392580,1381698)<br>J(392534,1380197)<br>K(393631,1378665)<br>L(391872,1377000) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២ | បឹងព្រះពន្លៃ | ២២១(១០៧) | ១១(២) | ២០០ | -ផ្ទះរុង<br>-ព្រហស្បតិក្បាល | ផ្ទះរុង | ភ្នំក្រវាញ | A(361851,1369564)<br>B(361407,1369346)<br>C(360875,1369271)<br>D(360509,1369328)<br>E(359914,1369531)<br>F(359613,1369754)<br>G(359406,1369784)<br>H(359307,1369905)<br>I (359292,1370285)<br>J (359185,1370553)<br>K(358775, 1371122)<br>L(358827, 1371574) | M(359057,1371823)<br>N(359682,1371799)<br>O(360005,1371352)<br>P(3600501370840)<br>Q(358920,1370911)<br>R(360124,1370229)<br>S(360286,1370049)<br>T(360526,1369901)<br>U(360030, 1371188)<br>V(360919, 1369738)<br>W(361213,1369704)<br>X(361419, 1369769) |
| **៥. ខេត្តបន្ទាយមានជ័យ** | | | | | | | | | |
| ១ | រូបរូម | ៣៩២(១៩៧) | ៩(១) | ៥.៥១០ | -ចារថ្មី<br>-ផ្កាវថ្មី | គោកបល្ល័ង្គ | មង្គលបូរី | A(298021,1492261)<br>B(299523,1490537)<br>C(299490,1489121)<br>D(302076,1489084) | E(300725,1482150)<br>F(292361,1486820)<br>G(291897,1489710)<br>H292581,1490351) |
| ២ | កំបោរ | ៩៧១(៥០១) | ៩(១) | ៦.៨៧០ | -កំបោរ<br>-កណ្ដាល | ភ្នំលៀប | ព្រះនេត្រព្រះ | A(316696,1501000)<br>B(318000,1498000)<br>C(316666,1496121)<br>D(315636,1492212)<br>E(314242,1490636)<br>F(313454,1490636) | G(312480,1492939)<br>H(312453,1489295)<br>I (308586,1491958)<br>J(310212,1493939)<br>K(310000,1501000) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | ដង្កៀបក្ដាមមានជ័យ | ១៦៥(២) | ៩(០) | ១៤.៣០០ | -ថ្មី<br>-ទន្លាប់<br>-ភៀនបន្ទាយ<br>-ប្រាសាទ<br>-អន្លង់សារ<br>-កំព្រាម<br>-តាអំ<br>-អំពិល<br>-ចារ<br>-សំពៅលូន<br>-កណ្ដាល<br>-ផ្លូវលាវ | ប្រាសាទ | ព្រះនេត្រព្រះ | A(328838,1496349)<br>B(324162,1494337)<br>C(321899,1492830)<br>D(318131,1489818)<br>E(317375,1487978)<br>F(317226,1482662)<br>G(318109,1482032)<br>H(318114,1479694) | I (319517,1480731)<br>J(321053,1480543)<br>K(321053,1479447)<br>L(326593,1477029)<br>M(328838,1477965)<br>N(326559,1483017)<br>O(326732,1484643)<br>P(327403,1489445) |

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន

**បានឃើញនិងឯកភាព**

ថ្ងៃ ព្រហស្បតិ៍......១២កើត..... ខែ..អស្សុជ.. ឆ្នាំ..កុរ..... ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី....១០.....ខែ...តុលា......ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**